# នីតិអន្តរជាតិសាធារណៈ
# PUBLIC INTERNATIONAL LAW

## មេរៀនទី ១១

LECTURE 11

## អញ្ញត្រកម្មនៃគោលការណ៍មិនធ្វើអន្តរាគមន៍

EXCEPTION PRINCIPAL OF STATE NON-INTERVENTION

# មាតិកា

- កម្មវត្ថុនៃមេរៀន
- ផ្នែកទី១ សេចក្តីផ្តើម
- ផ្នែកទី២ គោលការណ៍មិនធ្វើអន្តរាគមន៍
    - សញ្ញាណទូទៅ
    - ខ្លឹមសារនៃគោលការណ៍មិនធ្វើអន្តរាគមន៍
    - អញ្ញត្រកម្មនៃគោលការណ៍មិនធ្វើអន្តរាគមន៍
- ផ្នែកទី៣ អន្តរាគមន៍ស្នើសុំ
    - សញ្ញាណទូទៅ
    - គុណសម្បត្តិ
    - គុណវិប្បត្តិ
- ផ្នែកទី៤ អន្តរាគមន៍មនុស្សធម៌
    - សញ្ញាណទូទៅ
    - លក្ខខណ្ឌ

# កម្មវត្ថុនៃមេរៀន

នៅក្នុងមេរៀនស្តីពី អញ្ញត្រកម្មនៃគោលការណ៍មិនធ្វើអន្តរាគមន៍មានគោលបំណងឲ្យអ្នកសិក្សាបានស្វែងយល់ពីៈ

- អ្វីទៅជាអន្តរាគមន៍?
- អ្វីទៅជាអញ្ញត្រកម្មនៃគោលការណ៍មិនធ្វើអន្តរាគមន៍?
- តើគោលការណ៍នេះមានសារសំខាន់យ៉ាងនា?
- ថាតើអញ្ញត្រកម្មនេះប៉ះពាល់ដល់អធិបតេយ្យដែរ ឬទេ?
- អន្តរាគមន៍ និងអធិបតេយ្យរដ្ឋ

# ផ្នែកទី១ សេចក្ដីផ្ដើម

លើផែនដីនេះ មិនថាជារដ្ឋធំ ឬ ជារដ្ឋតូច ជារដ្ឋខ្លាំង ឬក៏ជារដ្ឋខ្សោយទេ តែងតែជួបនូវវិបត្ត ឬបញ្ហានៅក្នុងដំណើការនៃរដ្ឋរបស់ខ្លួន។ រដ្ឋមួយចំនួនអាចដោះស្រាយបញ្ហាទាំងនោះបានដោយខ្លួនឯង ចំណែកឯរដ្ឋមួយចំនួនទៀត ពុំលទ្ធភាពក្នុងការដោះស្រាយបញ្ហាដោយខ្លួនឯងឡើយ។

# ផ្នែកទី១ សេចក្តីផ្តើម

ពេលដែលរដ្ឋមិនអាចធ្វើការដោះស្រាយបញ្ហា បានដោយខ្លួនឯង ពួកគេអាចពឹងពាក់រដ្ឋដ៏ទៃ ឬ ក៏អាចរត់រកអង្គការអន្តរជាតិដើម្បីជួយដោះស្រាយបញ្ហាប្រឈមទាំងនោះ តាមរយៈការស្នើសុំនូវអន្តរាគមន៍ ហើយដែលអន្តរាគមន៍នោះអាចធ្វើឡើងក្នុងរូបភាពផ្សេងៗគ្នា។

# ផ្នែកទី១ សេចក្តីផ្តើម

អន្តរាគមន៍ អាចកើតឡើងក្នុងរូបភាពផ្សេងៗគ្នា ដែលក្នុងនោះរួមមានដូចជា អន្តរាគមន៍ស្នើសុំ (ផ្នែកទី៣) អន្តរាគមន៍មនុស្សធម៌ (ផ្នែកទី៤)។ មានការចោទសួរថា តើអន្តរាគមន៍ខាងលើនេះ នឹងធ្វើឲ្យប៉ះពាល់ដល់អធិបតេយ្យរដ្ឋដែលឬទេ?

# ផ្នែកទី១ សេចក្តីផ្តើម

នៅក្នុងធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ បានបញ្ញត្តិពីការផ្តានាដល់អធិបតេយ្យរបស់រដ្ឋ។ ដូច្នេះហើយ ទើបគេបង្កើតឡើងនូវ អញ្ញត្រកម្មនៃគោលការណ៍មិនធ្វើអន្តរាគមន៍ ដែលយើងនឹងធ្វើការសិក្សានូវអញ្ញត្រកម្មទាំងនោះ នៅក្នុងផ្នែកទី៣ ទី៤ នៃមេរៀននេះ។

# ផ្នែកទី២ គោលការណ៍មិនធ្វើអន្តរាគមន៍

- សញ្ញាណទូទៅ

ដូចដែលបានលើកឡើងពីខាងលើរួមមក ដើម្បីការពារនូវអធិបតេយ្យរដ្ឋ គេបានបង្កើតឲ្យមានគោលការណ៍មិនធ្វើអន្តរាគមន៍ ហើយដែលគោលការណ៍បានបញ្ញត្តិនៅក្នុងធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ។

# ផ្នែកទី២ គោលការណ៍មិនធ្វើអន្តរាគមន៍

- សញ្ញាណទូទៅ

គោលការណ៍នេះរាប់បញ្ចូលទាំង ការហាមប្រាមដល់ការជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងរបស់រដ្ឋ ទោះក្នុងរូបភាពមិនប្រើប្រាស់នូវកម្លាំងប្រដាប់អាវុធក៏ដោយ។ នៅក្នុងឆ្នាំ២០១៤ ករណីនេះវាបានកើតឡើងដោយអំពើរបស់រុស្ស៊ី ទៅលើប្រទេសអ៊ុយក្រែន។

# ផ្នែកទី២ គោលការណ៍មិនធ្វើអន្តរាគមន៍

- ខ្លឹមសារនៃគោលការណ៍មិនធ្វើអន្តរាគមន៍ មានការជជែកវែកញែកជាច្រើន ពីគោលការណ៍ហាមមិនឲ្យជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងរបស់រដ្ឋ ចេញពីគោលការណ៍ហាមមិនឲ្យធ្វើអន្តរាគមន៍។ ការហាមមិនឲ្យធ្វើអន្តរាគមន៍គឺជាគោលការណ៍មួយដែលមានន័យចង្អៀត។

# ផ្នែកទី២ គោលការណ៍មិនធ្វើអន្តរាគមន៍

- ខ្លឹមសារនៃគោលការណ៍មិនធ្វើអន្តរាគមន៍

ហេតុអ្វីបានជាគេអះអាងថា ការហាមមិនឲ្យធ្វើអន្តរាគមន៍ គឺជាគោលការណ៍ដែលមានលក្ខណៈចង្អៀត? ការអះអាងបែបនេះ ក៏ព្រោះថាការមិនធ្វើអន្តរាគមន៍ ជាកាតព្វកិច្ចគោរពនូវសមត្ថកិច្ចរបស់រដ្ឋ។

# ផ្នែកទី២ គោលការណ៍មិនធ្វើអន្តរាគមន៍

• ខ្លឹមសារនៃគោលការណ៍មិនធ្វើអន្តរាគមន៍

កាតព្វកិច្ចគោរពសមត្ថកិច្ចរដ្ឋ គឺគោរពសមត្ថកិច្ចដែនដី គោរពបូរណភាពដែនដីរបស់រដ្ឋ។ តែផ្ទុយទៅវិញ ការជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងរបស់រដ្ឋ អាចកើតឡើងទៅតាមទម្រង់ច្រើនបែបច្រើនយ៉ាង។

# ផ្នែកទី២ គោលការណ៍មិនធ្វើអន្តរាគមន៍

- ខ្លឹមសារនៃគោលការណ៍មិនធ្វើអន្តរាគមន៍

ជួនកាល អំពើនៃការជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងរបស់រដ្ឋមិនបានធ្វើឲ្យប៉ះពាល់ដល់សមត្ថកិច្ចដែនដី ឬ ក៏ប៉ះពាល់ដល់បូរណភាពទឹកដីរបស់រដ្ឋឡើយ ប៉ុន្តែវានូវតែត្រូវបានគេអះអាងថាជាអំពើនៃការជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងរដ្ឋ។

# ផ្នែកទី២ គោលការណ៍មិនធ្វើអន្តរាគមន៍

• ខ្លឹមសារនៃគោលការណ៍មិនធ្វើអន្តរាគមន៍

និយាយជារួម ការជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងរបស់រដ្ឋអាចត្រឹមតែជាការប្រើប្រាស់នូវពាក្យសម្ដី ឬ គ្រាន់តែជាការបញ្ចេញនូវមតិយោបល់ប៉ះពាល់គ្នា ដែលមិនបានអនុវត្តនូវអំពើ ឬ សកម្មភាពប្រដាប់អាវុធណាមួយឡើយ។

# ផ្នែកទី២ គោលការណ៍មិនធ្វើអន្តរាគមន៍

- ខ្លឹមសារនៃគោលការណ៍មិនធ្វើអន្តរាគមន៍

ផ្ទុយពីការជ្រៀតជ្រែក ការធ្វើអន្តរាគមន៍ គឺត្រូវតែកើតចេញពីអំពើជាក់ស្តែង ដោយប្រើប្រាស់នូវប្រតិបត្តការយោធា ដែលធ្វើឲ្យប៉ះពាល់ដល់បូរណភាពដែនដីរបស់រដ្ឋ ហើយដែលអំពើបែបនេះហើយ ដែលនាំឲ្យមានការហាមឃាត់។

# ផ្នែកទី២ គោលការណ៍មិនធ្វើអន្តរាគមន៍

- ខ្លឹមសារនៃគោលការណ៍មិនធ្វើអន្តរាគមន៍

សេចក្តីសម្រេចលេខ ៣៦/១០៣ របស់អង្គការសហប្រជាជាតិបានសរសេរថា *សេចក្តីថ្លែងការណ៍ ស្តីពីការមិនទទួលយល់ព្រមលើការធ្វើអន្តរាគមន៍ និងមិនជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងរបស់រដ្ឋ* តែការពិតជាក់ស្តែងយើងពិបាកក្នុងបែងចែកនូវគោលការណ៍ទាំងពីរនេះ។

# ផ្នែកទី២ គោលការណ៍មិនធ្វើអន្តរាគមន៍

- ខ្លឹមសារនៃគោលការណ៍មិនធ្វើអន្តរាគមន៍

ជាក់ស្តែងគេមាននិន្នាការធ្វើការទប់ស្កាត់ ការធ្វើអន្តរាគមន៍ជាការជ្រៀតជ្រែក នោះក៏ព្រោះតែការធ្វើអន្តរាគមន៍ បានធ្វើប៉ះពាល់ដោយផ្ទាល់ដល់អធិបតេយ្យរដ្ឋ និងប៉ះពាល់ដោយផ្ទាល់ដល់បូរណភាពដែនដីរដ្ឋតែម្តង។

# ផ្នែកទី២ គោលការណ៍មិនធ្វើអន្តរាគមន៍

- ខ្លឹមសារនៃគោលការណ៍មិនធ្វើអន្តរាគមន៍

រដ្ឋ ក៏ដូចជាអង្គការអន្តរជាតិ អាចនឹងធ្វើអន្តរាគមន៍បាន តែត្រូវគោរពនូវលក្ខខណ្ឌកំណត់ច្បាស់លាស់ និងមិនផ្ទុយពីគោលការណ៍អធិបតេយ្យរដ្ឋ។ ឧទាហរណ៍ ករណីរុស្ស៊ី និងអ៊ុយក្រែន គឺរុស្ស៊ីនៅពីដោយមិនចេញមុខចំពោះពួកឧទ្ទាមបំបែកទឹកដីតំបន់ គ្រីមមៀ។

# ផ្នែកទី២ គោលការណ៍មិនធ្វើអន្តរាគមន៍

- ខ្លឹមសារនៃគោលការណ៍មិនធ្វើអន្តរាគមន៍

គោលការណ៍នេះ ទទួលបានឥទ្ធិពលពីទ្រឹស្តីម៉ុនរ៉ូ ដែលត្រូវបានលើកឡើង ដើម្បីធ្វើការការពារខ្លួនទប់ទល់នឹងការធ្វើអន្តរាគមន៍របស់អឺរ៉ុបទៅលើទ្វីបអាមេរិក។ គោលការណ៍មិនធ្វើអន្តរាគមន៍នេះ ត្រូវបានលើកឡើងដោយអ្នកទ្រឹស្តីវិទូដ៏ល្បីឈ្មោះ គឺលោក ម៉ុនរ៉ូនៅឆ្នាំ១៨២៣។

# ផ្នែកទី២ គោលការណ៍មិនធ្វើអន្តរាគមន៍

- អញ្ញត្រកម្មនៃគោលការណ៍មិនធ្វើអន្តរាគមន៍ ទោះមានគោលការណ៍នៃការមិនធ្វើអន្តរាគមន៍ក៏ដោយ ក៏នៅតែមានករណីលើកលែងផងដែរ ដែលយើងហៅថា អញ្ញត្រកម្មនៃគោលការណ៍មិនធ្វើអន្តរាគមន៍។ មានន័យថា គេអាចធ្វើអន្តរាគមន៍ តែត្រូវគោរពនូវលក្ខខណ្ឌ។

# ផ្នែកទី២ គោលការណ៍មិនធ្វើអន្តរាគមន៍

- អញ្ញត្រកម្មនៃគោលការណ៍មិនធ្វើអន្តរាគមន៍

ជាទូទៅ ឲ្យតែមានអន្តរាគមន៍កើតឡើង ដែលផ្ទុយទៅនឹងគោលការណ៍ហាមមិនឲ្យធ្វើអន្តរាគមន៍ ចូលទៅក្នុងកិច្ចការផ្ទៃក្នុងរបស់រដ្ឋ នោះត្រូវបានចាត់ទុកថា ជាការធ្វើអន្តរាគមន៍ដោយខុសច្បាប់អន្តរជាតិ។

# ផ្នែកទី២ គោលការណ៍មិនធ្វើអន្តរាគមន៍

- អញ្ញត្រកម្មនៃគោលការណ៍មិនធ្វើអន្តរាគមន៍

អញ្ញត្រកម្មនៃគោលការណ៍នេះមានពីរគឺ អន្តរាគមន៍ស្នើសុំ និងអន្តរាគមន៍មនុស្សធម៌។ អញ្ញត្រកម្ម មានន័យថា គេអាចធ្វើអន្តរាគមន៍បាន តែវាត្រូវគោរពនូវលក្ខខណ្ឌ។ នៅក្នុងផ្នែកទី៣ និងទី៤ នឹងនិយាយពីអន្តរាគមន៍ទាំងពីរដែលគេទទួលស្គាល់។

# ផ្នែកទី៣ អន្តរាគមន៍ស្នើសុំ

- សញ្ញាណទូទៅ

អន្តរាគមន៍នេះ អាចកើតមានឡើងក្នុងស្ថានភាពហឹ្វកហ្វរផ្ទៃក្នុង ឬ ស្ថិតក្នុងស្ថានភាពលំបាករបស់រដ្ឋណាមួយ ដែលអាចមានដូចជា ករណីសង្គ្រាមស៊ីវិល ដែលមេដឹកនាំរបស់ប្រទេសមួយបានធ្វើការពឹងពាក់ប្រទេសមួយទៀតឲ្យជួយ។

# ផ្នែកទី៣ អន្តរាគមន៍ស្នើសុំ

- សញ្ញាណទូទៅ

តាមរយៈនៃការពឹងពាក់ ឬ ស្នើសុំជំនួយក្រោមរូបភាពនៃការធ្វើអន្តរាគមន៍ ដែលអាចឲ្យមេដឹកនាំប្រទេសនោះរក្សាបាននូវអំណាចរបស់ខ្លួន និងពុំត្រូវបានផ្ដួលរំលំពីភាគីម្ខាងទៀតនៃជម្លោះសង្គ្រាមស៊ីវិល។

# ផ្នែកទី៣ អន្តរាគមន៍ស្នើសុំ

- សញ្ញាណទូទៅ

អន្តរាគមន៍នេះ មិនប៉ះពាល់ដល់អធិបតេយ្យរដ្ឋឡើយ ព្រោះថា ជាទូទៅវាត្រូវកើតឡើងដោយមានការព្រមព្រៀងរវាងអ្នកធ្វើអន្តរាគមន៍ និងអ្នកស្នើសុំ។ កិច្ចព្រមព្រៀងនេះ អាចកើតឡើងក្នុងទម្រង់ទ្វេរភាគី ដូចជាសន្ធិសញ្ញាមិត្តភាពជួយគ្នាទៅវិញទៅមក ជាអាទិ៍។

# ផ្នែកទី៣ អន្តរាគមន៍ស្នើសុំ

- សញ្ញាណទូទៅ

កិច្ចព្រមព្រៀងស្តីពីការធ្វើអន្តរាគមន៍ ក៏អាចកើតឡើងក្នុងទម្រង់ពហុភាគីផងដែរ ដូចជាសម្ព័ន្ធភាពយោធា ដែលចែងពីលក្ខខណ្ឌនៃការការពារខ្លួនជាធម្មានុរូបជាដើម ដូចជាករណី សន្និសញ្ញាអាតាឡង់ទិកខាងជើង និងកត្តិការ៉ាស្សូវីជាដើម។

# ផ្នែកទី៣ អន្តរាគមន៍ស្នើសុំ

- សញ្ញាណទូទៅ

មានអន្តរាគមន៍ស្នើសុំជាច្រើនបានកើតឡើង ដូចជាករណីមានការធ្វើអន្តរាគមន៍ស្នើសុំ នៅក្នុងប្រទេសកម្ពុជានៅឆ្នាំ ១៩៧៩ អន្តរាគមន៍ស្នើសុំនៅប្រទេសហុងគ្រីនៅក្នុងឆ្នាំ ១៩៥៦ ជាអាទិ៍។

# ផ្នែកទី៣ អន្តរាគមន៍ស្នើសុំ

- គុណសម្បត្តិ

ក្នុងកាលៈទេសៈមួយចំនួនអន្តរាគមន៍នេះ បានចូលរួមដល់ការគោរពនូវគោលការណ៍សិទ្ធិមនុស្ស និងភាពសុខដុមរម្យនារបស់ប្រទេសជាតិ។ ទប់ស្កាត់នូវការវាតទីនិយម និងលុបបំបាត់នូវការកាន់កាប់អំណាចហួសហេតុ។

# ផ្នែកទី៣ អន្តរាគមន៍ស្នើសុំ

- គុណសម្បត្តិ

ជួយរំដោះប្រទេសជាតិ និងប្រជាជនពីភាពរឹករវ អស្ថេរភាពនៅក្នុងសង្គមជាតិ ថែរក្សានូវសណ្តាប់ធ្នាប់នៅក្នុងសង្គមអន្តរជាតិ ក៏ដូចជាសន្តិភាពនៅក្នុងពិភពលោក ព្រោះថាកើតចេញពីវិវាទផ្ទៃក្នុងរបស់រដ្ឋ អាចឈានដល់មានវិវាទអន្តរជាតិផងដែរ។

# ផ្នែកទី៣ អន្តរាគមន៍ស្នើសុំ

- គុណវិបត្តិ

ការលំបាកចម្បងមួយគឺ តើអាជ្ញាធរណាដែលមានភាពស្របច្បាប់ក្នុងការស្នើសុំឲ្យអន្តរាគមន៍។ យើងត្រូវពិចារណា និងបែងចែកឲ្យបានម៉ត់ចត់ រវាងជំនួយដែលស្នើសុំដើម្បីការពារពីការឈ្លានពាន និងជំនួយដើម្បីពង្រឹងអំណាចនៃអំពើខុសច្បាប់។

# ផ្នែកទី៣ អន្តរាគមន៍ស្នើសុំ

- គុណវិប្បត្តិ

អន្តរាគមន៍ស្នើសុំ ហាក់មានភាពរលូន តែគេត្រូវពិចារណាដល់សិទ្ធិស្វ័យសម្រេចរបស់ប្រជាជនផងដែរ ដែលវាជាគោលការណ៍មួយនៃនីតិអន្តរជាតិ។ អន្តរាគមន៍មួយចំនួនធ្វើឡើងដើម្បីរក្សាអំណាច ដែលបានធ្វើទុក្ខបុកម្នេញដល់ប្រជាជន រំលោភបំពានសិទ្ធិមនុស្ស ជាអាទ៏។

# ផ្នែកទី៤ អន្តរាគមន៍មនុស្សធម៌

- សញ្ញាណទូទៅ

ជាប្រតិបត្តិការ ដែលមានលក្ខណៈយោធារបស់រដ្ឋណាមួយ ឬ រដ្ឋច្រើន ឬ អាចធ្វើឡើងដោយអង្គការអន្តរជាតិ (អង្គការសហប្រជាជាតិ) នៅលើទឹកដីនៃរដ្ឋណាមួយ ចេតនាដើម្បីធ្វើការរំដោះប្រជាជនពីគ្រោះថ្នាក់ណាមួយ។

# ផ្នែកទី៤ អន្តរាគមន៍មនុស្សធម៌

- សញ្ញាណទូទៅ

មានអន្តរាគមន៍មនុស្សធម៌បានកើតឡើងនៅមជ្ឈិមបូព៌ា ក្នុងគោលបំណងដើម្បីរំដោះប្រជាជនអ៊ីរ៉ាក់ ពីអំណាចផ្តាច់ការ ជិះជាន់ឥតត្រាប្រណី ជិះជាន់ និងបិទសិទ្ធិសេរីភាពទៅលើស្ត្រីភេទរបស់អ្នកដឹកនាំប្រទេស។

# ផ្នែកទី៤ អន្តរាគមន៍មនុស្សធម៌

- សញ្ញាណទូទៅ

អន្តរាគមន៍ដើម្បីរំដោះប្រជាជនស៊ីវិល ក៏អាចនឹងកើតឡើងដោយរដ្ឋណាមួយ ដើម្បីរំដោះជនជាតិរបស់ខ្លួន ឬ ប្រជាជននៃប្រទេសដ៏ទៃផ្សេងទៀត ដែលកំពុងជាប់គាំងនៅក្នុងប្រទេសណាមួយ ដែលកំពុងមានសង្គ្រាមស៊ីវិល ជាអាទិ៍។

# ផ្នែកទី៤ អន្តរាគមន៍មនុស្សធម៌

• លក្ខខណ្ឌ

ដើម្បីទទួលបាននូវភាពស្របច្បាប់ អន្តរាគមន៍មនុស្សធម៌ត្រូវគោរពនូវលក្ខខណ្ឌ ដែលមានដូចជា៖

១. ត្រូវមានការអនុញ្ញាតពីរដ្ឋម្ចាស់ផ្ទះ ដោយសារគាត់មិនមានលទ្ធភាពគ្រប់គ្រងស្ថានការណ៍

# ផ្នែកទី៤ អន្តរាគមន៍មនុស្សធម៌

- លក្ខខណ្ឌ

២. ត្រូវមានហេតុការណ៍ដែលនាំឲ្យមានអន្តរាគមន៍

៣. ត្រូវមានការអនុញ្ញាតពីក្រុមប្រឹក្សាសន្តិសុខរបស់អង្គការសហប្រជាជាតិ ឬ មានការឧបត្ថមផ្ទាល់ពីក្រុមប្រឹក្សាសន្តិសុខ

# ផ្នែកទី៤ អន្តរាគមន៍មនុស្សធម៌

- លក្ខខណ្ឌ

៤. ត្រូវធ្វើក្នុងរយៈពេលវេលាសមស្រប ទៅនឹងស្ថានភាពនៃហេតុការណ៍

៥. ត្រូវប្រើប្រាស់មធ្យោបាយឲ្យសមមាត្រ នឹងហេតុការណ៍ដែលកើតឡើង

# ផ្នែកទី៤ អន្តរាគមន៍មនុស្សធម៌

- លក្ខខណ្ឌ

៦. នៅពេលចប់បេសកកម្ម ត្រូវប្រគល់ការគ្រប់គ្រងទៅឲ្យរដ្ឋម្ចាស់ផ្ទះវិញ ក្នុងពេលវេលាដ៏សមស្រប ព្រមទាំងធ្វើការដកកងកម្លាំងរបស់ខ្លួនចេញវិញ ដោយមិនមានការអូសបន្លាយពេលវេលា។

មេរៀនទី១១ ស្តីពីអញ្ញត្រកម្មនៃគោលការមិនធ្វើអន្តរាគមន៍បានបញ្ចប់។ សូមអរគុណ សម្រាប់ការតាមដានដោយយកចិត្តទុកដាក់ពីសំណាក់អ្នកសិក្សាទាំងឡាយ។